# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### កិច្ចព្រមព្រៀង
### រវាង តំណាងបុគ្គលិក សណ្ឋាគារ សុខាអង្គរ
### និង និយោជកនៃ សណ្ឋាគារ សុខាអង្គរ

អនុស្សរណៈនៃការយោគយល់នេះត្រូវបានធ្វើឡើងនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ រវាងបុគ្គលិកនៃសណ្ឋាគារ សុខាអង្គរ (ពីនេះតទៅហៅថា "តំណាងបុគ្គលិក") និងតំណាងសណ្ឋាគារ សុខា អង្គរ (ពីនេះតទៅហៅថា "និយោជក")។

ដោយសារស្ថានភាពវិបត្តិជំងឺ Covid-19 នៅលើពិភពលោកនៅតែពុំទាន់ថមថយ ធ្វើអោយប្រក្រតីភាពនៃដំណើរការសេដ្ឋកិច្ច និងពាណិជ្ជកម្មគ្រប់វិស័យនៅលើពិភពលោក រួមទាំងប្រទេសកម្ពុជាយើងផងនៅតែទទួលរងនូវបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរ ជាពិសេសលើវិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ច។ អាស្រ័យហេតុនេះយើងខ្ញុំបានសម្រេចចិត្តផ្អាកសកម្មភាពអាជីវកម្មរបស់ សណ្ឋាគារ សុខាអង្គរ ជាបណ្ដោះអាសន្ន រយៈពេលពីរ(០២)ខែបន្តទៀត ដោយគិតចាប់ពីថ្ងៃទី១២ **ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១** ។ ហេតុនេះ ដើម្បីសម្រាលនូវបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរនៅចំពោះមុខនេះ និយោជក និងតំណាងបុគ្គលិក បានចរចារ និងព្រមព្រាងគ្នាដាក់ឲ្យបុគ្គលិកចំនួន ២១៧នាក់ ស្រី ៨៨នាក់ បន្តឈប់សម្រាកពីការងារដោយឥតប្រាក់ឈ្នួល រយៈពេលពីរ (២) ខែទៀត គិតចាប់ពីថ្ងៃទី១២ **ខែមេសា ឆ្នាំ២០២១ ដល់ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១។**

ភាគីទាំងពីរបានព្រមព្រៀងគ្នា លើលក្ខខណ្ឌដូចខាងក្រោម៖

- និយោជិតដែលត្រូវបានដាក់ឲ្យឈប់សម្រាកពីការងាររយៈពេលពីរ (២) ខែ នឹងមិនទទួលបានប្រាក់ឈ្នួល និងប្រាក់ធានានុគ្រោះទេ នៅក្នុងអំឡុងពេលនៃការឈប់សម្រាកនេះ។
- អតីតភាពការងាររបស់និយោជិតដែលដាក់ឲ្យឈប់សម្រាកដោយឥតប្រាក់ឈ្នួល នឹងមិនត្រូវបានប៉ះពាល់ឡើយ។
- និយោជក នឹងរក្សាទុកក្នុងកម្មករនិយោជិតចំនួនអប្បបរមា ទៅតាមតម្រូវការជាក់ស្តែងនៃផ្នែកនិមួយៗ ដើម្បីបំពេញការងារក្នុងកំឡុងពេលផ្អាកដំណើរការអាជីវកម្ម។

សូមបញ្ជាក់ថា ចំណុចដូចដែលបានរៀបរាប់ខាងលើនេះ គឺសម្រាប់ការអនុវត្តរយៈពេលពីរ (២) ខែ គិតចាប់ពីថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១។ ក្រុមហ៊ុននឹងធ្វើការជូនដំណឹងជាថ្មី ប្រសិនបើស្ថានការណ៍មានការប្រែប្រួល ហើយគូភាគីនឹងពិនិត្យមើលអនុស្សរណៈនៃការយោគយល់នេះ ពីខាងក្រោមនេះ៖

សណ្ឋាគារសុខាអង្គរ SOKHA ANGKOR HOTEL BRANCH OF SOKHA HOTEL CO.,LTD.

**ហត្ថលេខាភាគីតំណាងនិយោជក**

សាខាក្រុមហ៊ុន សុខា អូតែល
សណ្ឋាគារសុខាអង្គរ
SOKHA ANGKOR HOTEL
BRANCH OF SOKHA HOTEL CO.,LTD.

____________________

**ហត្ថលេខាភាគីតំណាងនិយោជិត**

អ៊ុក សុធា ____________________ 25.3.21

វ៉ាន់ ចំណាន ____________________ Chamnan 24.03.21

ប៊ិន សាលីន ____________________ Salin 24.03.21

កាន់ គង់ហេង ____________________ Kongheng 23.03.2021

សាខាក្រុមហ៊ុន សុខា អូតែល
សណ្ឋាគារសុខាអង្គរ
SOKHA ANGKOR HOTEL
BRANCH OF SOKHA HOTEL CO.,LTD.

**ហត្ថលេខាភាគីតំណាងនិយោជិត**

គង់ សុខា ____________________

ស៊ុន សុធារី ____________________

វឿន វីរដ្ឋ ____________________

សុខ វណ្ណា ____________________

ស៊ូ ដារី ____________________

អ៊ាត សុជាតិ ____________________